រួមគ្នាស្រឡាញ់នឹងថែរក្សាវប្បធម៌ខ្មែរ!

# ២៤ - រឿង បុរសបងថ្លៃ និងប្អូនថ្លៃ




មានមនុស្សពីរនាក់ ជាបងថ្លៃ ប្អូនថ្លៃនឹងគ្នា, បងថ្លៃជាអ្នកក្រ ប្អូនថ្លៃជាអ្នកមានទ្រព្យសម្បត្តិ។ ថ្ងៃមួយ ឪពុកក្មេក មានកិច្ចរវល់ត្រូវប្រាប់បងប្អូន កូនចៅឲ្យទៅស៊ីផឹកនៅផ្ទះគាត់, ប្អូនថ្លៃនោះ បានមកជួបនឹងបង បបួលទៅស៊ីឯផ្ទះឪពុកក្មេក, បងថ្លៃនិយាយប្រាប់តាមត្រង់ថា៖ «មិនហ៊ានទៅស៊ីទេ» ព្រោះខ្លួនជាអ្នកក្រ មិនធ្លាប់ស៊ីម្ហូបចំណីល្អ ក្រែងមិនត្រូវបែបបទ ខ្មាសគេ,ប្អូនថ្លៃនោះជាមនុស្សចិត្តសប្បុរសនឹងបងក៏ប្រាប់ទៅវិញថា៖ មិនអីទេ ទៅពីរនាក់ចុះ បើមិនដឹង ឲ្យតែធ្វើតាមខ្ញុំៗ ស៊ីអី ស៊ីហ្នឹងទៅ មិនក្រប៉ុន្មានទេ បងទៅជាមួយនឹងខ្ញុំចុះ។ បងក៏ព្រមទៅ, លុះទៅបរិភោគនៅទីនោះ បបួលគ្នាស៊ីបាយតាមធម្មតាទៅ, ដល់គេលើកសម្លខ្ញៅមក ប្អូនក៏យកចង្កឹះចាប់មួយមកពម រួចជញ្ជក់អស់ ខ្ជាក់សំបកខ្ញៅនោះដាក់នៅនឹងកន្លែង ហើយគេចោលសំបកនោះទៅ ។

ឯបងនោះមិនដឹង ដោយមិនបានឃើញគេធ្វើដូច្នោះ ក៏ខំជញ្ជក់ហើយខំទំាងទំពាសំបកខ្ញៅនោះទាល់តែល្អិត ខំលេបទៅ ។ ប្អូនឃើញដូច្នេះ ក៏លែងស៊ីខ្ញៅនោះទៅចាប់យកឯអំពៅ ដែលគេឡៅទុកនៅចាននោះមកស៊ីៗ រួចគេយកកន្សែងខ្ជប់ដាក់ ហើយចោលទៅទៀត ។ បងឃើញគេស៊ីអំពៅ ក៏យកអំពៅនោះ មកស៊ីនឹងគេទៀត ខំទំពាអំពៅទាល់តែល្អិតកាកលេបទៅទៀត ប្អូនលែងស៊ីអំពៅ វាទៅស៊ីសម្លមីសួរទៀត ទើបតែនឹងពមចូលក្នុងមាត់ នឹកឃើញបងស៊ីអំពៅទាំងកាកនោះ ហើយអស់សំណើចទប់មិនឈ្នះ ក៏ចេញសំឡេងមកព្ញតែឃឹក ។ ដោយហេតុខ្យល់ទប់ឃឹកនោះ មីសួរវាស្ទុះឡើងទៅចូលឯរន្ធច្រមុះទាំងពីរ ចេញមីសួរនោះមកក្រៅដោយអំណាចខ្យល់ ។ បងថ្លៃឃើញដូច្នោះក៏ចោលចង្កឹះទៅក្នុងថាសថា «ទេ ! លែងស៊ីហើយ ស៊ីឯទៀតធ្វើតាម សូម្បីខ្ញៅនិងអំពៅ ទាំងសំបក ទាំងកាក ក៏ស៊ីបានទាំងអស់ ដល់មីសួរ ខ្លះនឹងច្រមុះដូច្នេះធ្វើតាមមិនបានទេ ប្អូនឯងស៊ីតែឯងចុះ បងលែងស៊ីហើយ ស៊ីទៅទៀតមិនកើតទេ» ។

> ***ពុតត្រូវកុំត្រាប់ ច្បាប់ត្រូវឲ្យយក***

Wunsch-Domains bei STRATO
Die Domain mit den gewissen Extras. Bis 02.08. zum Top-Hoster wechseln!

g+1 +1 Recommend this on Google

Top-Tablets bei o2
jetzt online bei o2 bestellen. Exklusive Tablets für einmalig 1€.

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ

